72

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# ក្របខណ្ឌសមត្ថភាពស្នូលសម្រាប់
# និស្សិតទើបបញ្ចប់ការសិក្សាផ្នែកគ្រូពេទ្យព្យាបាលជំងឺទូទៅ
# នៅក្នុងប្រទេសកម្ពុជា

ខែ សីហា ឆ្នាំ ២០១២ក្រសួងសុខាភិបាល នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស

Australian AID

World Health Organization

# ក្របខណ្ឌសមត្ថភាពស្នូលសម្រាប់
# និស្សិតទើបបញ្ចប់ការសិក្សាផ្នែកគ្រូពេទ្យព្យាបាលជំងឺទូទៅ
# នៅក្នុងប្រទេសកម្ពុជា

---

## សេចក្តីផ្តើម

នៅក្នុងប្រទេសកម្ពុជា វេជ្ជបណ្ឌិតជាច្រើនធ្វើការនៅក្នុងមន្ទីរពេទ្យ ឬគ្លីនីករបស់រដ្ឋ ឯកជន និងអង្គការក្រៅរដ្ឋាភិបាល ហើយខ្លះទៀតធ្វើការឲ្យរាជរដ្ឋាភិបាល និងគ្រឹះស្ថានអប់រំនានា។

វេជ្ជបណ្ឌិតដែលអនុវត្តការងារនៅក្នុងទីកន្លែងណាក៏ដោយ ត្រូវតែគោរពតាមវិធាន បទបញ្ជា និងបទដ្ឋានវិជ្ជាជីវៈ ដូចដែលបានចែងដោយក្រសួងសុខាភិបាល និងគណៈគ្រូពេទ្យកម្ពុជា។ ពួកគេត្រូវមាន និងអនុវត្តចំណេះដឹងវេជ្ជសាស្ត្រជាមូលដ្ឋាន ដើម្បីបំពេញតួនាទីរបស់ពួកគេអោយបានត្រឹមត្រូវ និងដើម្បីបណ្តុះបណ្តាលនិស្សិតពេទ្យ និងអ្នកដទៃទៀត។ ពួកគេគួរអនុវត្តផងដែរនូវសកម្មភាពស្រាវជ្រាវ និងការអភិវឌ្ឍន៍វិជ្ជាជីវៈជាបន្ត សំដៅថែរក្សា និងលើកកំពស់សមត្ថភាពជំនាញ និងការអនុវត្តន៍របស់ខ្លួន។

## *ក. គោលបំណងនៃការកំណត់ក្របខណ្ឌសមត្ថភាពស្នូល*

**សមត្ថភាព**[1] នៅក្នុងឯកសារនេះ សំដៅទៅលើចំណេះដឹង ជំនាញ អាកប្បកិរិយា និងឥរិយាបថដែលបុគ្គលម្នាក់ៗអភិវឌ្ឍឡើងតាមរយៈការអប់រំ ការបណ្តុះបណ្តាល និងបទពិសោធន៍ការងារ។ **ក្របខណ្ឌសមត្ថភាពស្នូល**[2]សម្រាប់គ្រូពេទ្យព្យាបាលជំងឺទូទៅ[3] គឺជាបណ្តុំនៃសមត្ថភាពជំនាញជាសារវន្តដែល គ្រូពេទ្យព្យាបាលជំងឺទូទៅ ត្រូវតែមាន ដើម្បីអនុវត្តការងារប្រចាំថ្ងៃរបស់ខ្លួននៅគ្រប់ទីកន្លែងធ្វើការទាំងអស់។

ក្របខណ្ឌនេះត្រូវបានបង្កើតឡើងជាបឋម សម្រាប់ការប្រឡងចេញថ្នាក់ជាតិរបស់និស្សិតថ្នាក់វេជ្ជបណ្ឌិតដែលទើបតែបញ្ចប់ការសិក្សាមកពីសាលាពេទ្យទាំងរដ្ឋនិងឯកជនក្នុងប្រទេសកម្ពុជា។ គេអាចប្រើក្របខណ្ឌនេះដើម្បីអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់វគ្គសិក្សានានាដែលនាំទៅរកការបញ្ចប់ការសិក្សាថ្នាក់វេជ្ជបណ្ឌិតផ្នែកជំងឺទូទៅ ឬដើម្បីជាមូលដ្ឋានមួយសម្រាប់អភិវឌ្ឍការបណ្តុះ

---

[1] Competency

[2] Core Competency Framework

[3] General Practitioner

បណ្ដាលកម្រិតខ្ពស់ឬការអប់រំឯកទេសនៅក្នុងផ្នែកវេជ្ជសាស្ត្រ និង ដើម្បីចេញអាជ្ញាប័ណ្ណសម្រាប់ប្រកបវិជ្ជាជីវៈផ្នែកវេជ្ជសាស្ត្រនៅក្នុងប្រទេសកម្ពុជា។

## *ខ. បែបបទនៃការអភិវឌ្ឍ ក្របខណ្ឌសមត្ថភាពស្នូល*

ក្របខណ្ឌសមត្ថភាពស្នូលសម្រាប់គ្រូពេទ្យព្យាបាលជំងឺទូទៅនៅក្នុងប្រទេសកម្ពុជា ត្រូវបានអភិវឌ្ឍឡើងតាមរយៈ កិច្ចប្រជុំពិគ្រោះយោបល់ជាច្រើនរបស់ **ក្រុមការងារបច្ចេកទេស**[4]មួយសំរាប់ការប្រឡងចេញថ្នាក់ជាតិនៃគ្រូពេទ្យព្យាបាលជំងឺទូទៅ ដែលបានចាប់ផ្តើមការងាររបស់ខ្លួននៅពាក់កណ្ដាលឆ្នាំ២០១១។

ក្រុមការងារបច្ចេកទេសនេះ ត្រូវបានបង្កើតឡើងដោយគណៈកម្មាធិការប្រឡងថ្នាក់ជាតិ ដែលរួមមានវេជ្ជបណ្ឌិតនិងសាស្ត្រាចារ្យ មកពីសកលវិទ្យាល័យសាធារណៈនិងឯកជនក្នុងប្រទេសកម្ពុជា ដឹកនាំដោយប្រធានមួយរូបមកពីក្រសួងសុខាភិបាល (សូមមើល<u>ឧបសម្ព័ន្ធទី១</u>៖ សមាសភាពក្រុមការងារវេជ្ជសាស្ត្រ)។ ក្របខណ្ឌនេះត្រូវបានអនុម័តដោយ**គណៈកម្មការសំរបសំរួល**[5]មួយដែលបង្កើតឡើងដោយគណៈកម្មាធិការប្រឡងថ្នាក់ជាតិ និង ដឹកនាំដោយរដ្ឋលេខាធិការមួយរូបនៃក្រសួងសុខាភិបាល (សូមមើល<u>ឧបសម្ព័ន្ធទី២</u>៖ សមាសភាពគណៈកម្មការសំរបសំរួល)។

ការអភិវឌ្ឍក្របខណ្ឌនេះ ផ្អែកលើមូលដ្ឋានខាងក្រោម៖

- ការពិនិត្យឡើងវិញ លើក្របខណ្ឌសមត្ថភាពស្នូល របស់គ្រូពេទ្យព្យាបាលជំងឺទូទៅ នៅតាមបណ្ដាប្រទេសមួយចំនួន ដូចជា អូស្ត្រាលី កាណាដា ហ្វីលីពីន ចក្រភពអង់គ្លេស និង សហរដ្ឋអាមេរិក។
- លក្ខណៈរំពឹងទុករបស់គ្រូពេទ្យព្យាបាលជំងឺទូទៅ(សូមមើល<u>ឧបសម្ព័ន្ធទី៣</u>)
- ចំណេះដឹង និងបទពិសោធជាក់ស្តែងរបស់សមាជិកក្រុមការងារដែលបានចូលរួម និង
- កម្មវិធីសិក្សាស្តង់ដាររបស់ក្រសួងសុខាភិបាលសម្រាប់ថ្នាក់វេជ្ជបណ្ឌិត។

ឯកសារដំបូងមួយត្រូវបានធ្វើពង្រាងឡើងនៅពាក់កណ្ដាលឆ្នាំ២០១១ និងត្រូវបានពិនិត្យឡើងវិញជាបន្តបន្ទាប់ និងកែសម្រួលដោយក្រុមការងារវេជ្ជសាស្ត្រ បន្ទាប់ពីពិគ្រោះយោបល់ជាមួយតំណាងគណៈគ្រូពេទ្យកម្ពុជា និង ដៃគូអភិវឌ្ឍន៍សុខាភិបាល។ ក្របខណ្ឌសមត្ថភាពស្នូលសម្រាប់គ្រូពេទ្យព្យាបាលជំងឺទូទៅ ត្រូវបានកែលម្អព្រមពេលជាមួយនឹងក្របខណ្ឌសមត្ថភាពរបស់អ្នកផ្តល់សេវាថែទាំវេជ្ជសាស្ត្រ ទន្តបណ្ឌិត និងឱសថការី ដែលត្រូវបានបង្កើតឡើងក្នុង

[4] Technical Working Group

[5] Steering Committee

គោលបំណងដូចគ្នា និងមានទម្រង់តែមួយ។ ឯកសារនេះបង្ហាញពី សមត្ថភាពស្នូលអប្បបរិមា សម្រាប់គ្រូពេទ្យព្យាបាលជំងឺទូទៅ នៅពេលបញ្ចប់**កម្មវិធីសិក្សាថ្នាក់វេជ្ជបណ្ឌិត** ក្នុងការផ្តល់ការថែទាំ និងព្យាបាលជំងឺប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

## *គ. វចនាសម្ព័ន្ធរបស់ក្របខណ្ឌ*

ក្របខណ្ឌសមត្ថភាពស្នូលនេះកំណត់ពី **ចំណេះដឹង**[6]ដែលគ្រូពេទ្យព្យាបាលជំងឺទូទៅត្រូវចេះ **ជំនាញ**[7]ណាខ្លះដែលពួកគេត្រូវមាន ព្រមទាំង **អកប្បកិរិយានិងឥរិយាបថ**[8]ណាខ្លះដែលពួកគេត្រូវប្រកាន់យក ក្នុងការប្រកបវិជ្ជាជីវៈប្រចាំថ្ងៃរបស់ពួកគេ។

ក្របខណ្ឌក្នុងឯកសារនេះ រួមមាន**បីជំពូកចម្បង** គឺ(១)មូលដ្ឋានគ្រឹះវិទ្យាសាស្ត្រសម្រាប់ការប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ (២)ការផ្តល់សេវាពិនិត្យព្យាបាលជំងឺ និង(៣)ឥរិយាបថវិជ្ជាជីវៈ និងបុគ្គល។

ឯកសារនេះ គួរត្រូវបានចាត់ទុកថាជា**ឯកសាររស់**[9]មួយ ដែលត្រូវគេរំពឹងថានឹងមានការកែលំអជាប្រចាំ។ ដូច្នេះគេគួរធ្វើការពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នភាពឲ្យបានទៀងទាត់ ជារៀងរាល់ឆ្នាំនៅក្នុងឆ្នាំដំបូងៗដើម្បីដោះស្រាយបញ្ហាដែលមិនដឹងជាមុនឲ្យបានឆាប់រហ័សនិងប្រកបដោយប្រសិទ្ធភាព ហើយបន្ទាប់មកទៀតធ្វើបច្ចុប្បន្នភាពរៀងរាល់បីឆ្នាំម្តង ដើម្បីអោយសមស្របតាមការអភិវឌ្ឍន៍នៃវេជ្ជសាស្ត្រ និងស្តង់ដារវិជ្ជាជីវៈនៅក្នុងប្រទេស។

គ្រប់ជំពូកនិងស្តង់ដារសមត្ថភាពស្នូលទាំងអស់ដែលបានរៀបរាប់ខាងលើ កំណត់ពីលក្ខខណ្ឌតម្រូវសម្រាប់និស្សិតវេជ្ជសាស្ត្រដែលទើបបញ្ចប់ការសិក្សាហើយត្រូវប្រលងចេញថ្នាក់ជាតិ ដើម្បីទទួលបាននូវ សញ្ញាប័ត្រ និង អាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈ នៅក្នុងប្រទេសកម្ពុជា។

---

[6] Knowledge

[7] Skills

[8] Attitude and Behaviors

[9] Living document

# មាតិកា


សេចក្តីផ្តើម ........ 1

ក. គោលបំណងនៃការកំណត់ក្របខណ្ឌសមត្ថភាពស្នូល ........ 1

ខ. បែបបទនៃការអភិវឌ្ឍ ក្របខណ្ឌសមត្ថភាពស្នូល ........ 2

គ. រចនាសម្ព័ន្ធរបស់ក្របខណ្ឌ ........ 3

ជំពូកទី១៖ មូលដ្ឋានគ្រឹះវិទ្យាសាស្រ្តសម្រាប់ការប្រកបវិជ្ជាជីវៈវេជ្ជសាស្រ្ត ........ 5

ក. វិទ្យាសាស្រ្ត ជីវវេជ្ជសាស្រ្ត (Biomedical Sciences) ........ 5

ខ. វិទ្យាសាស្រ្តឥរិយាបថ (Behavioural Sciences) ........ 6

គ. សុខភាពសាធារណៈ (Public Health) ........ 6

ឃ. ព័ត៌មាន និងការប្រាស្រ័យទាក់ទង ( Information and Communication) ........ 7

ង. ការរៀបចំ គ្រប់គ្រង និងស្រាវជ្រាវ (Organization, Management and Research) ........ 7

ជំពូកទី២៖ ការផ្តល់សេវាថែទាំព្យាបាលជំងឺទូទៅ ........ 8

ក. គោលការណ៍ទូទៅនៃការធ្វើរោគវិនិច្ឆ័យនិងព្យាបាលជំងឺ ........ 8

ខ. ទម្រង់ការ ធ្វើរោគវិនិច្ឆ័យ (Diagnostic Procedures) ........ 8

៥ .ផែនការព្យាបាលជំងឺ (Management Plan) ........ 11

គ. ការថែទាំព្យាបាលជំងឺ (Patient Management) ........ 11

ជំពូកទី៣៖ ឥរិយាបថវិជ្ជាជីវៈ និង ឥរិយាបថផ្ទាល់ខ្លួន ........ 15

ក. ការប្រតិបត្តិ ប្រកបដោយ វិជ្ជាជីវៈ តាមច្បាប់ និង ក្រមសីលធម៌ ........ 15

ខ .ការអភិវឌ្ឍន៍សមត្ថភាពវិជ្ជាជីវៈបន្ត (Continuing Professional Development) ........ 16

គ. ការវិភាគល្អិតល្អន់ ការស្រាវជ្រាវ និងការបណ្តុះបណ្តាល ........ 17

ឃ. ការប្រាស្រ័យទាក់ទង (Communication) ........ 17

ឧបសម្ព័ន្ធទី១៖ សមាសភាពក្រុមការងារវេជ្ជសាស្រ្ត ........ 19

ឧបសម្ព័ន្ធទី២៖ សមាសភាពគណៈកម្មការសំរបសំរួល ........ 20

ឧបសម្ព័ន្ធទី៣៖ លក្ខណៈសម្បត្តិរបស់គ្រូពេទ្យព្យាបាលជំងឺទូទៅ ........ 21

ឧបសម្ព័ន្ធទី៤៖ មូលដ្ឋានវិទ្យាសាស្រ្តសំរាប់ការអនុវត្តន៍វិជ្ជាជីវៈវេជ្ជសាស្រ្ត ........ 23

ឧបសម្ព័ន្ធទី៥៖ មាតិការសមត្ថភាពសម្រាប់ការពិនិត្យព្យាបាលជំងឺ ........ 26

បញ្ជីឯកសារយោង ........ 45

## ជំពូកទី១៖ មូលដ្ឋានគ្រឹះវិទ្យាសាស្ត្រសម្រាប់ការប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ (Scientific Foundations for Medical Practice)

គ្រូពេទ្យព្យាបាលជំងឺទូទៅ ត្រូវមាន ចំណេះដឹងវេជ្ជសាស្ត្រជាមូលដ្ឋាន ដើម្បី ផ្តល់ការពិនិត្យព្យាបាលជំងឺអោយមាន ប្រសិទ្ធភាព និង សុវត្ថិភាព។

### *ក. វិទ្យាសាស្ត្រ វេជ្ជជីវ សាស្ត្រ (Biomedical Sciences)*

វិទ្យាសាស្ត្រវេជ្ជជីវសាស្ត្រ រួមមាន កាយវិភាគវិទ្យា(anatomy) ជីវគីមីវិទ្យា (biochemistry) ជីវវិទ្យា (biology) ពន្ធុវិទ្យា (genetics) ជាលិកាវិទ្យា (histology) អ៊ីមុយណូវិទ្យា (immunology) មីក្រូជីវវិទ្យា (microbiology) អាហារូបត្ថម្ភ (nutrition) រោគវិទ្យា (pathology) រោគសរីរវិទ្យា (pathophysiology) ហ្វាម៉ាកូវិទ្យា (pharmacology) និង សរីរវិទ្យា (physiology)។

គ្រូពេទ្យព្យាបាលជំងឺទូទៅអនុវត្តចំណេះដឹង វិទ្យាសាស្ត្រវេជ្ជជីវសាស្ត្រដើម្បី៖

១. ពន្យល់អំពីរចនាសម្ព័ន្ធធម្មតារបស់មនុស្ស និងតួនាទីរបស់វា

២. ពន្យល់អំពីមូលដ្ឋានវិទ្យាសាស្ត្រសម្រាប់ការបង្ហាញជំងឺដែលជួបញឹកញាប់

៣. បំភ្លឺពីការជ្រើសយកនូវការអង្កេតវិភាគវេជ្ជសាស្ត្រ[10]សមស្រប សម្រាប់ករណីគ្លីនីកដែលជួបញឹកញាប់ដោយផ្អែកលើ៖ (i) អត្រាប្រេវ៉ាឡង់នៃជំងឺ (ii) ភាពដែលអាចព្យាបាលបាន ភាពដែលអាចធ្វើទៅបាន និង ភាពដែលអាចចូលទៅទទួលយកនូវការព្យាបាល[11] ព្រមទាំង (iii) ភាពបន្ទាន់ក្នុងការព្យាបាល

៤. ពន្យល់អំពីគោលការណ៍ជាមូលដ្ឋាននៃបច្ចេកទេសអង្កេតវិភាគទាំងនោះ

៥. ជ្រើសយកវិធីព្យាបាល និងបង្ការសមស្របសម្រាប់ជំងឺដែលជួបញឹកញាប់ ព្រមទាំងពន្យល់ពីសកម្មភាព និងហានិភ័យរបស់វិធីទាំងនោះ

៦. បង្ហាញពីចំណេះដឹងអំពីសកម្មភាពឱសថ៖ របៀបព្យាបាល[12] និងចលនសាស្ត្រ[13]នៃឱសថ ផលរំខាននិងអន្តរកម្មឱសថ[14] រួមទាំងការព្យាបាលដោយឱសថច្រើនមុខ ការព្យាបាលដោយមានរយៈពេលយូរ និងមិនមានវេជ្ជបញ្ជា ព្រមទាំងឥទ្ធិពលនៃការប្រើឱសថលើប្រជាជនដូចជាការសាយភាយនូវភាពស៊ាំនៃអង្គបីយ៉ូទិក។

---

[10] Investigation;

[11] Treatability, feasibility and accessibility of treatment

[12] Therapeutics

[13] Pharmacokinetics

[14] Drug side effects and interactions

៧. ធ្វើការសង្កេតឲ្យបានត្រឹមត្រូវលើរោគសញ្ញាគ្លីនីក និងធ្វើការវិភាគទិន្នន័យគ្លីនីកឲ្យបានត្រឹមត្រូវជិតដល់។

## ខ. វិទ្យាសាស្ត្រឥរិយាបថ (Behavioural Sciences)

គ្រូពេទ្យព្យាបាលជំងឺទូទៅ ប្រើចំណេះដឹងវិទ្យាសាស្ត្រឥរិយាបថ រួមមានគោលការណ៍ចិត្តសាស្ត្រ និងវិទ្យាសាស្ត្រសង្គមដើម្បីៈ

១. ពន្យល់អំពីឥរិយាបថធម្មតារបស់មនុស្សក្នុងកំរិតបុគ្គល និង ក្នុងកំរិតសង្គម
២. ពិភាក្សាពីគោលគំនិតបែបសង្គម ចិត្តវិទ្យាចំពោះសុខភាព និងការមានជំងឺ
៣. អនុវត្តក្របខណ្ឌទ្រឹស្តីនៃចិត្តវិទ្យានិងសង្គមវិទ្យាដើម្បីពន្យល់ពីចម្លើយតបផ្សេងៗនៃបុគ្គល ក្រុម និងសង្គមចំពោះជំងឺ
៤. ពន្យល់អំពីកត្តាសង្គម និងចិត្តសាស្ត្រដែលធ្វើឲ្យមានជំងឺ ការវិវដ្តន៍នៃជំងឺ និងជោគជ័យនៃការព្យាបាល
៥. ពិភាក្សាអំពីទិដ្ឋភាពសង្គម និងចិត្តសាស្ត្រនៃការផ្លាស់ប្តូរឥរិយាបថ និងភាពជាប់លាប់ក្នុងការព្យាបាល
៦. កំណត់យុទ្ធសាស្ត្រត្រឹមត្រូវសម្រាប់ព្យាបាលអ្នកជំងឺដែលមានបញ្ហាញៀន ការបង្ករគ្រោះថ្នាក់អោយខ្លួនឯង[15] ព្រមទាំង ឥរិយាបថប្រឈមនឹងការរើសអើង និង ការមាក់ងាយ។

## គ. សុខភាពសាធារណៈ (Public Health)

គ្រូពេទ្យព្យាបាលជំងឺទូទៅ មានចំណេះដឹងផ្នែកសុខភាពសាធារណៈ និងវេជ្ជសាស្ត្របង្ការ ជាអាទិចំណេះដឹងផ្នែកអេពីដេមីសាស្ត្រ បញ្ហាសុខភាពប្រជាជន និងកត្តាកំណត់បញ្ហាសុខភាពគ្រោះមហន្តរាយ និងបញ្ហាសុខភាពសកលដើម្បីៈ

១. អប់រំអ្នកជំងឺ និងសាច់ញាតិស្តីពីកត្តាកំណត់នៃជំងឺ ការលើកកម្ពស់សុខភាព ការបង្ការជំងឺ និងជួយអ្នកជំងឺឲ្យកែលំអរឥរិយាបថ
២. ចូលរួមក្នុងការអង្កេតតាមដាន និងស្រាវជ្រាវជំងឺតាមការណែនាំរបស់ក្រសួងសុខាភិបាល
៣. ធ្វើការបង្ការជំងឺកម្រិតបឋម កម្រិតទី២ និងកម្រិតទី៣
៤. គ្រប់គ្រងការថែទាំសុខភាពសម្រាប់បុគ្គល និងសហគមន៍
៥. អនុវត្តយុទ្ធសាស្ត្រសុខភាពសាធារណៈ និងយុទ្ធសាស្ត្រកាត់បន្ថយគ្រោះថ្នាក់ និងបង្ការជំងឺសម្រាប់អ្នកជំងឺម្នាក់ៗ និងសហគមន៍ប្រកបដោយប្រសិទ្ធភាព

---
[15] Self-harm

៦. បង្ការ និងទប់ស្កាត់ការចម្លងរោគ និងជំងឺឆ្លងនៅក្នុងមន្ទីរពេទ្យឬគ្លីនីក និងសហគមន៍
៧. កត់ត្រា និងរាយការណ៍អំពីជំងឺ និងលក្ខខណ្ឌជំងឺ ដោយប្រើប្រព័ន្ធតាមដានជំងឺទៅតាមការណែនាំដោយក្រសួងសុខាភិបាល។

## *ឃ. ព័ត៌មាន និងការប្រាស្រ័យទាក់ទង (Information and Communication)*

គ្រូពេទ្យព្យាបាលជំងឺទូទៅ មានចំណេះដឹងក្នុង ការប្រើប្រាស់កុំព្យូទ័រ និង បច្ចេកវិជ្ជាក្នុងការប្រាស្រ័យទាក់ទងផ្សព្វផ្សាយព័ត៌មាន ដើម្បី៖

១. ទាញយកប្រយោជន៍ប្រកបដោយប្រសិទ្ធភាពពី កុំព្យូទ័រ និងប្រព័ន្ធព័ត៌មានដទៃទៀត រួមទាំងការរក្សាទុក និងស្រាវជ្រាវយកព័ត៌មានមកប្រើ
២. ចូលទៅប្រភពព័ត៌មាន និងប្រើព័ត៌មានដែលពាក់ព័ន្ធដោយជាប់ទាក់ទងនឹងការថែទាំព្យាបាលអ្នកជំងឺ ការលើកកម្ពស់សុខភាព ការផ្តល់ដំបូន្មាន និងព័ត៌មានដល់អ្នកជំងឺ ព្រមទាំងការស្រាវជ្រាវ និងការអប់រំ
៣. អនុវត្តការស្រាវជ្រាវគ្លីនីក និងសុខភាព និងផ្សព្វផ្សាយរបកគំហើញនៃការស្រាវជ្រាវ។

## *ង. ការរៀបចំ គ្រប់គ្រង និងស្រាវជ្រាវ (Organization, Management and Research)*

គ្រូពេទ្យព្យាបាលជំងឺទូទៅ មានចំណេះដឹងមូលដ្ឋានស្តីពីគោលការណ៍ និងវិធីសាស្ត្រស្រាវជ្រាវសុខភាពដើម្បី៖

១. បកស្រាយលទ្ធផលនៃរោគវិនិច្ឆ័យដែលពាក់ព័ន្ធ ការព្យាករណ៍លក្ខណៈរោគទុកជាមុន និងការព្យាបាលសាកល្បង ការសិក្សាបែបគុណភាពនិងបរិមាណដទៃទៀតដូចដែលបានរាយការណ៍នៅក្នុងទ្រឹស្តីវេជ្ជសាស្ត្រ និងវិទ្យាសាស្ត្រ
២. បង្កើតសំណួរស្រាវជ្រាវសាមញ្ញដែលពាក់ព័ន្ធក្នុងការស្រាវជ្រាវសុខភាព និងតាក់តែងការសិក្សាសមស្របដើម្បីដោះស្រាយបញ្ហា
៣. អនុវត្តនូវរបកគំហើញដើម្បីឆ្លើយសំណួរដែលលើកឡើងដោយបញ្ហាគ្លីនីកជាក់លាក់។
៤. អនុវត្តក្រមសីលធម៌ និងអភិបាលកិច្ចដែលពាក់ព័ន្ធនឹងការស្រាវជ្រាវវេជ្ជសាស្ត្រ។

មាតិកា[16]សមត្ថភាពស្នូល នៃ មូលដ្ឋានវិទ្យាសាស្ត្រសំរាប់ការអនុវត្តន៍វិជ្ជាជីវៈវេជ្ជសាស្ត្រ មានចែងក្នុង ឧបសម្ព័ន្ធទី៣។

---

[16] Content

## ជំពូកទី២៖ ការផ្តល់សេវាថែទាំព្យាបាលជំងឺទូទៅ

(Provision and Management of Patient Care )

ផ្នែកនេះទាក់ទងនឹងតួនាទីរបស់គ្រូពេទ្យដែលជាអ្នកផ្តល់សេវាថែទាំព្យាបាលជំងឺទូទៅ។ គ្រូពេទ្យព្យាបាលជំងឺទូទៅអនុវត្តនូវដំណើរការធ្វើរោគវិនិច្ឆ័យនិងព្យាបាលជំងឺ តាមលំដាប់លំដោយ និង សមស្រប ដើម្បីផ្តល់សេវាថែទាំព្យាបាលជំងឺ ប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និង គ្រប់ជ្រុងជ្រោយ។

### *ក. គោលការណ៍ទូទៅនៃការធ្វើរោគវិនិច្ឆ័យនិងព្យាបាលជំងឺ*

(General Principles of Diagnostic and Therapeutic for GP)

១. ការជ្រើសរើស និងប្រើប្រាស់ទម្រង់ការគ្លីនីកឲ្យបានត្រឹមត្រូវ និងសមស្រប
២. ការអនុវត្តន៍ ឬស្នើសុំការអង្កេតវិភាគដោយផ្អែកលើគោលការណ៍ណែនាំឬទម្រង់ការថ្នាក់ជាតិ។
៣. ការទទួលយល់ព្រមពីអ្នកជំងឺដែលត្រូវបានផ្តល់អោយដឹងជាមុននូវពត៌មានសម្រាប់ទម្រង់ការ អង្កេតស្រាវជ្រាវ និងព្យាបាល
៤. ការធានាឲ្យមានអត្តសញ្ញាណអ្នកជំងឺត្រឹមត្រូវ
៥. ការរៀបចំអ្នកជំងឺសម្រាប់ការអង្កេត វិភាគជំងឺដោយសមស្រប និងដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់
៦. ការប្រាប់លទ្ធផលនៃការអង្កេតវិភាគ និងការព្យាបាលដល់អ្នកជំងឺឬក្រុមគ្រួសារ
៧. ការបកស្រាយអំពីរបាយការណ៍ឬលទ្ធផលនៃការអង្កេតវិភាគ
៨. ការផ្តល់ព័ត៌មានគ្លីនីក និងប្រជាសាស្ត្រដែលចាំបាច់ទាំងអស់នៅក្នុងទម្រង់ស្នើសុំវិភាគ
៩. ការលាងដៃឲ្យបានស្អាត
១០. ការប្រើប្រាស់សម្ភារៈសម្រាប់ការពារផ្ទាល់ខ្លួន
១១. ការបង្ការការឆ្លងរោគនៅពេលអនុវត្តទម្រង់ការធ្វើរោគវិនិច្ឆ័យ និងព្យាបាល
១២. ការបោះចោលកាកសំណល់គ្លីនីក ម្ជុល និងសម្ភារៈផ្សេងៗទៀត ប្រកបដោយសុវត្ថិភាព។

### *ខ. ទម្រង់ការ ធ្វើរោគវិនិច្ឆ័យ (Diagnostic Procedures)*

គ្រូពេទ្យព្យាបាលជំងឺទូទៅអនុវត្តនូវទម្រង់ការធ្វើរោគវិនិច្ឆ័យដែលរួមមាន៖ ការសាកសួរប្រវត្តិជំងឺ ការពិនិត្យជំងឺ ការអង្កេតវិភាគជំងឺ ការធ្វើរោគវិនិច្ឆ័យ ហើយនិង ផែនការព្យាបាលជំងឺ។

## ១.ការសាកសួរប្រវត្តិជំងឺ (History Taking)

គ្រូពេទ្យព្យាបាលជំងឺទូទៅ សាកសួរនិងកត់ត្រាប្រវត្តិនៃជំងឺ រួមទាំងប្រវត្តិគ្រួសារនិងសង្គម តាមរយៈការសាកសួរអ្នកជំងឺ និងក្នុងករណីចាំបាច់តាមរយៈការសាកសួរក្រុមគ្រួសារឬអ្នកថែទាំ ដោយហ្មត់ចត់ មានរបៀប និងប្រយ័ត្នប្រយែង។

## ២. ការពិនិត្យរាងកាយ និងស្ថានភាពផ្លូវចិត្ត (Physical and Mental State Examination)

គ្រូពេទ្យព្យាបាលជំងឺទូទៅ ធ្វើការពិនិត្យរាងកាយនិងស្ថានភាពផ្លូវចិត្ត ដោយយកចិត្តទុកដាក់ ប្រុងប្រយ័ត្ន ប៉ិនប្រសប់ និងមានលក្ខណៈជាប្រព័ន្ធ។

- ការពិនិត្យរាងកាយ៖ ការស្ដាប់ ការស្ទាប និង ការគោះ ការពិនិត្យភ្នែកត្រចៀកច្រមុះ និងបំពង់ក ការពិនិត្យសរសៃប្រសាទ (ឧទា.ពិនិត្យreflexes) ការពិនិត្យរោគខាងក្នុង (សម្រាប់ស្ត្រី) ការពិនិត្យចុងពោះវៀនធំឬរន្ធគូទ
- ធ្វើការវាស់វែងសញ្ញាជីវិត (vital signs)៖ ការយកសីតុណ្ហភាព ជីពចរ សម្ពាធឈាម ចង្វាក់ដង្ហើម

## ៣. ការអង្កេតវិភាគជំងឺ (Patient Investigation)

គ្រូពេទ្យព្យាបាលជំងឺទូទៅ ប្រើប្រាស់បែបបទសមស្របជាចាំបាច់មួយចំនួន ដើម្បីអង្កេតវិភាគជំងឺ និងធ្វើរោគវិនិច្ឆ័យ ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព ព្រមទាំងវាស់វែង និងកត់ត្រានូវរបកគំហើញ។

### ៣.១ ការអង្កេតវិភាគដោយផ្អែកលើមន្ទីរពិសោធន៍ (Laboratory-based Investigations)៖

គ្រូពេទ្យព្យាបាលជំងឺទូទៅ មានសមត្ថភាព

-កំណត់រកមើលលក្ខខ័ណ្ឌនិងស្ថានភាពជំងឺ ដែលតម្រូវអោយធ្វើការអង្កេតវិភាគដោយផ្អែកលើមន្ទីរពិសោធន៍ ជីវៈគីមីវិទ្យា (biochemistry) លោហិតវិទ្យា (hematology) មីក្រូជីវវិទ្យា (microbiology) រោគវិទ្យា (pathology) កោសិកាវិទ្យា(cytology) ពន្ធុវិទ្យា (genetics) អ៊ីមុយណូវិទ្យា (immunology) វិសាណូវិទ្យា (virology) និង វិសវិទ្យា(toxicology) តាមដែលមាន

-ព្រមទាំងធ្វើការយកវត្ថុវិភាគដើម្បីធ្វើការអង្កេតវិភាគរកមូលហេតុជំងឺ ទៅតាមការចាំបាច់។

### ៣.២ ការអង្កេតវិភាគដោយផ្អែកលើវិទ្យុសាស្ត្រ (Radiological Investigations)

គ្រូពេទ្យព្យាបាលជំងឺទូទៅមានសមត្ថភាព កំណត់រកមើលលក្ខខ័ណ្ឌនិងស្ថានភាពជំងឺដែលតម្រូវអោយធ្វើការអង្កេតវិភាគដោយផ្អែកលើវិទ្យុសាស្ត្រ ជាអាទិ ការថតសួត ការថតពោះ និង ការថតឆ្អឹង ដោយកាំរស្មីអិច។

### ៣.៣ ការអង្កេតវិភាគគ្លីនីក (Clinical Investigation )

គ្រូពេទ្យព្យាបាលជំងឺទូទៅមានសមត្ថភាព កំណត់រកមើលលក្ខណ្ឌ/កាលទេសៈជំងឺ ដែលតម្រូវអោយធ្វើការអង្កេតវិភាគកគ្លីនីក ព្រមទាំងធ្វើការយកវត្ថុវិភាគដើម្បីធ្វើការអង្កេតវិភាគរកមូលហេតុជំងឺ ទៅតាមការចាំបាច់ ជាអាទិ

- ការបូមយកវត្ថុរាវដែលដក់នៅខាងក្នុង (fluid collections)យកទៅពិនិត្យ ដូចជា ការបូមទឹកក្នុងស្រោមសួត ការបូមទឹកក្នុងឆ្អឹងខ្នង ការបូមទឹកក្នុងសន្លាក់
- ការច្រិបយកជាលិកា(biopsy of tissue) យកទៅពិនិត្យ
- ការពិនិត្យមើលបំពង់ខ្យល់
- ការធ្វើតេស្តសម្រាប់រកមើលឧស្ម័នក្នុងឈាម
- ការធ្វើតេស្តTourniquetsសម្រាប់ជំងឺគ្រុនឈាម
- ការបូមឈាមដើម្បីបណ្តុះរកមេរោគ(blood cultures)
- ការវាស់វែងកម្រិតជាតិស្ករក្នុងឈាម និងបកស្រាយលទ្ធផល
- ការវាស់វែងរូបភាពអគ្គិសនីបេះដូង(Electrocardiograph) និងបកស្រាយលទ្ធផល
- ការវិភាគទឹកនោមដោយប្រើ Multistix
- ការកោសយកកោសិកាពី ច្រមុះ អណ្តាត និងស្បែក សម្រាប់វិភាគ
- ការវាយតម្លៃអាហារូបត្ថម្ភឬបកស្រាយលទ្ធផលផ្អែកលើតារាងនៃការលូតលាស់
- ការធ្វើតេស្តបញ្ជាក់ការមានគភ៌

## ៤. ការធ្វើរោគវិនិច្ឆ័យ (Diagnosis)

គ្រូពេទ្យព្យាបាលជំងឺទូទៅមានសមត្ថភាពៈ

៤.១ បកស្រាយរបកគំហើញពីប្រវត្តិ និងការពិនិត្យរាងកាយ និងស្ថានភាពផ្លូវចិត្ត ដោយឲ្យតម្លៃលើសារៈសំខាន់នៃកត្តាគ្លីនីក អេពីដេមីសាស្រ្ត ចិត្តសាស្រ្ត ស្មារតី សាសនា សង្គម និងវប្បធម៌

៤.២ ធ្វើការវាយតម្លៃបឋមមួយលើបញ្ហារបស់អ្នកជំងឺ និងកំណត់នូវរោគវិនិច្ឆ័យសមស្រប ដោយផ្អែកលើប្រេវ៉ាឡង់ជំងឺ ភាពបន្ទាន់ដែលត្រូវព្យាបាល និងប្រសិទ្ធភាពនៃការព្យាបាលដែលអាចធ្វើបាន

៤.៣ ធ្វើការអង្កេតវិភាគបន្ថែមទៀតនៅពេលណាដែលមានលទ្ធភាពអាចធ្វើបានទៅតាមការចាំបាច់ដើម្បីគាំទ្ររោគវិនិច្ឆ័យ និងការព្យាបាល។

៤.៤ សំយោគការវាយតម្លៃពេញលេញមួយលើបញ្ហារបស់អ្នកជំងឺ និងកំណត់ ពីរោគវិនិច្ឆ័យឲ្យបានជាក់លាក់។

### *៥.ផែនការព្យាបាលជំងឺ (Management Plan)*

គ្រូពេទ្យព្យាបាលជំងឺទូទៅមានសមត្ថភាព៖

**៥.១** ធ្វើរោគវិនិច្ឆ័យគ្លីនីក និងការសម្រេចចិត្តក្នុងការព្យាបាលដោយផ្អែកលើភស្តុតាង ដែលមាន ដោយពិគ្រោះជាមួយសហការី និងស្របតាមកម្រិតបណ្តុះបណ្តាលនិងបទពិសោធន៍របស់ខ្លួន

**៥.២** លើកឡើងនូវផែនការសម្រាប់ការព្យាបាល ការគ្រប់គ្រង និងការឲ្យអ្នកជំងឺចេញពីពេទ្យដោយផ្អែកលើគោលការណ៍វេជ្ជសាស្ត្រ និងបទពិសោធន៍កន្លងមកក្នុងភាពជាដៃគូជាមួយនឹងអ្នកជំងឺ អ្នកកំដរអ្នកជំងឺ និងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដទៃទៀតតាមការចាំបាច់

**៥.៣** កំណត់ភិនភាគករណីដែលត្រូវបញ្ជូនទៅអ្នកឯកទេស និងរៀបចំសម្រាប់ការបញ្ជូនអ្នកជំងឺឲ្យបានត្រឹមត្រូវ រួមទាំងការបញ្ជូនទាន់ពេលវេលា បន្ទាប់ពីអ្នកជំងឺមានលំនឹង ដោយជូនដំណឹងទៅមន្ទីរពេទ្យដែលទទួលមុនពេលបញ្ជូន ហើយរៀបចំឲ្យមានបុគ្គលិកសុខាភិបាលទៅជាមួយអ្នកជំងឺ ព្រមទាំងត្រូវមានឱសថសង្គ្រោះជីវិត និងសម្ភារៈសម្រាប់ដឹកជញ្ជូន និងប័ណ្ណកំណត់ត្រាជំងឺ ដែលក្នុងនោះរួមមានមានឯកសារច្បាស់លាស់អំពីប្រវត្តិ និងការព្យាបាលផ្សេងៗ

**៥.៤** ឆ្លើយតបទៅនឹងកង្វល់ហើយនិងការចង់បានរបស់អ្នកជំងឺ ពន្យល់និងផ្តល់ព័ត៌មានដើម្បីទទួលបានការយល់ព្រមពីអ្នកជំងឺ និងគោរពសិទ្ធអ្នកជំងឺ ក្នុងការសម្រេចចិត្តអំពីការថែទាំនិងព្យាបាលរបស់ពួកគេ

**៥.៥** កត់ត្រាការថែទាំអ្នកជំងឺ និងការវាយតម្លៃ ដែលកំពុងដំណើរការដោយពេញលេញច្បាស់លាស់ ត្រឹមត្រូវ និងទាន់ពេល។

## *គ. ការថែទាំព្យាបាលជំងឺ (Patient Management)*

### ១. ទម្រង់ការទូទៅក្នុងការថែទាំព្យាបាលជំងឺ (General Patient Management)

១.១. គ្រូពេទ្យព្យាបាលជំងឺទូទៅផ្តល់**ការថែទាំព្យាបាលភ្លាមៗ**ចំពោះអ្នកជំងឺដែលទាមទារអោយមានការសង្គ្រោះបន្ទាន់ដោយ៖

- វាយតម្លៃ និងរកឃើញនូវភាពធ្ងន់ធ្ងរនៃជំងឺឬបញ្ហាសុខភាព ព្រមទាំងតម្រូវការសម្រាប់ការថែទាំជំងឺដែលទាមទារការសង្គ្រោះបន្ទាន់ (immediate emergency care)
- ធ្វើរោគវិនិច្ឆ័យនិងព្យាបាល ជំងឺសង្គ្រោះបន្ទាន់ស្រួចស្រាវ (acute medical emergencies)

- ផ្ដល់ការសង្គ្រោះបឋមជាមូលដ្ឋាន
- ផ្ដល់ការទ្រទ្រង់ជីវិតជាបន្ទាន់(immediate life support)
- ផ្ដល់ការសង្គ្រោះបេះដូងនិងសួត ឬណែនាំសមាជិកក្រុមផ្សេងៗទៀតឲ្យអនុវត្តការសង្គ្រោះ។

១.២. គ្រូពេទ្យព្យាបាលជំងឺទូទៅ**ចេញវេជ្ជបញ្ជា**ឱសថដែលមានសុវត្ថិភាព ប្រសិទ្ធភាព និងសន្សំសំចៃដោយ៖

- សួរពីប្រវត្តិប្រើប្រាស់ឱសថឲ្យបានត្រឹមត្រូវ រួមទាំងឱសថដែលមាន និង គ្មានវេជ្ជបញ្ជា
- លើកឡើងនូវគំរោងព្យាបាលឲ្យបានសមស្របសម្រាប់ជំងឺទូទៅរួមទាំងការឈឺចាប់ និងវិបត្តិផ្សេងៗ
- ចេញវេជ្ជបញ្ជាដែលស្របច្បាប់ និងមានសុវត្ថិភាព
- គណនាកម្រិតប្រើប្រាស់ឱសថឲ្យបានត្រឹមត្រូវ និងកត់ត្រាលទ្ធផលឲ្យបានល្អ
- ផ្ដល់ដល់អ្នកជំងឺនូវព័ត៌មានត្រឹមត្រូវអំពីឱសថរបស់គេ
- ស្រាវជ្រាវរកព័ត៌មានដែលគួរឲ្យទុកចិត្តបានអំពីឱសថ
- រាវរក និងរាយការណ៍អំពីប្រតិកម្មមិនល្អរបស់ឱសថ
- ទទួលស្គាល់ពីប្រការដែលថាអ្នកជំងឺមួយចំនួនប្រើការព្យាបាលបន្ថែម និងជំនួស (ជាអាទិឱសថបុរាណ) និងការយល់ដឹងអំពីវត្តមាន និងប្រភេទនៃការព្យាបាលទាំងនេះ ថាហេតុអ្វីដែលអ្នកជំងឺប្រើវា និងពីរបៀបដែលការព្យាបាលនេះអាចប៉ះពាល់ដល់ការព្យាបាលបែបផ្សេងៗទៀតដែលអ្នកជំងឺកំពុងទទួល។

**១.៣.** គ្រូពេទ្យព្យាបាលជំងឺទូទៅ អនុវត្ត**ទម្រង់ការព្យាបាល**ឲ្យបានសមស្រប។

**១.៤.** គ្រូពេទ្យព្យាបាលជំងឺទូទៅប្រើរាល់មធ្យោបាយប្រាស្រ័យទាក់ទងជាមួយនឹងអ្នកជំងឺដើម្បីផ្ដល់**ការអប់រំ**សម្រាប់លើកកម្ពស់សុខភាព និងការបង្ការជំងឺ។

**១.៥.** គ្រូពេទ្យព្យាបាលជំងឺទូទៅបំពេញ**កំណត់ត្រាវេជ្ជសាស្ត្រ** ឧទា. ឯកសារអ្នកជំងឺ សំបុត្រកំណើតនិងមរណភាពដោយអនុលោមតាមច្បាប់នៅក្នុងប្រទេសកម្ពុជា និងគោលការណ៍ណែនាំរបស់មន្ទីរពេទ្យ ឬគ្លីនីក។

## ២. ទម្រង់ការដោយឡែកៗសម្រាប់ថែទាំព្យាបាលជំងឺ (Specific Patient Management)

ខាងក្រោមនេះជាសេចក្ដីបរិយាយអំពីសមត្ថភាពស្នូលរបស់គ្រូពេទ្យព្យាបាលជំងឺទូទៅ ដែលទាក់ទងនឹងតួនាទីជាអ្នកអនុវត្តការងារវេជ្ជសាស្ត្រនៅក្នុងប្រព័ន្ធថែទាំសុខភាពនៃប្រទេសកម្ពុជា។

### ២.១. វេជ្ជសាស្ត្រ/ជំងឺទូទៅ (Medicine)

គ្រូពេទ្យព្យាបាលជំងឺទូទៅ កំណត់ភិនភាគបញ្ហាជំងឺទូទៅ ដែលជួបញឹកញាប់ព្រមទាំងផលវិបាក និងវិធីព្យាបាល ព្រមទាំងផ្តល់ការព្យាបាលជំងឺឲ្យបានសមស្រប។

### ២.២. សល្យសាស្ត្រ/ ជំងឺវះកាត់ (Surgery)

គ្រូពេទ្យព្យាបាលជំងឺទូទៅ ស្គាល់ករណីដែលតម្រូវអោយមាន ការវះកាត់និងអន្តរាគមន៍វះកាត់ ដោយកំណត់ភិនភាគបញ្ហាវះកាត់ដែលជួបញឹកញាប់ ព្រមទាំងផលវិបាកនិងវិធីព្យា បាល ហើយផ្តល់ការព្យាបាលដោយការវះកាត់ជំងឺឲ្យបានសមស្រប រួមទាំងការថែទាំ មុនពេល ក្នុងពេល និងក្រោយពេលវះកាត់។

### ២.៣ ជំងឺកុមារ (Pediatric)

គ្រូពេទ្យព្យាបាលជំងឺទូទៅ កំណត់ភិនភាគជំងឺកុមារដែលជួបញឹកញាប់ ព្រមទាំងផលវិបាក និងវិធីព្យាបាល ហើយផ្តល់ការព្យាបាលជំងឺឲ្យបានត្រឹមត្រូវ និងផ្តល់ការប្រឹក្សាសមស្របតាមអាយុរបស់កុមារ។

### ២.៤ រោគស្ត្រី និងសម្ភព (Gynecology and Obstetrics)

- យោងលើស្ថានភាពគ្លីនីកជាក់ស្តែងរបស់អ្នកជំងឺ គ្រូពេទ្យព្យាបាលជំងឺទូទៅ៖
  - កំណត់ភិនភាគបញ្ហារោគស្ត្រីដែលជួបញឹកញាប់ ព្រមទាំងផលវិបាក និងវិធីព្យាបាល
  - ផ្តល់ការព្យាបាលករណីនិមួយៗឲ្យបានសមស្រប ដោយផ្អែកលើស្តង់ដារជាតិ
- យោងលើស្ថានភាពជាក់ស្តែងរបស់ស្ត្រីមានផ្ទៃពោះ និងដោយមានជំនួយពីឆ្មប គ្រូពេទ្យព្យាបាលជំងឺទូទៅ៖
  - កំណត់ភិនភាគសញ្ញានៃការមានគភ៌និងរបកគំហើញពីការពិនិត្យរាងកាយ
  - ជ្រើសយកការធ្វើរោគវិនិច្ឆ័យត្រឹមត្រូវ និងការពិនិត្យដោយមន្ទីរពិសោធន៍ដែលចាំបាច់ក្នុងការធ្វើរោគវិនិច្ឆ័យ និងតាមដានការមានគភ៌
  - ផ្តល់ការថែទាំមុនពេលសម្រាលឲ្យបានគ្រប់គ្រាន់
  - ស្គាល់ពីភាពស្មុគស្មាញឬបញ្ហាដែលកើតឡើងក្នុងពេលមានគភ៌
  - គ្រប់គ្រងការឈឺពោះសម្រាល និងការសម្រាលកូនធម្មតា
  - ស្គាល់ពីផលវិបាកដែលដែលកើតឡើង ក្នុងខណៈពេលឈឺពោះសម្រាល និងការសម្រាលកូនធម្មតា

- ○ កំណត់ភិនភាគស្ថានភាពអំឡុងពេលឈឺពោះសម្រាល ដែលត្រូវបញ្ជូនទៅគ្រូពេទ្យឯកទេស និងរៀបចំការបញ្ជូនស្ត្រីឲ្យបានត្រឹមត្រូវ រួមទាំងការបញ្ជូនទាន់ពេលវេលាបន្ទាប់ពីអ្នកជំងឺមានលំនឹង ជូនដំណឹងទៅមន្ទីរពេទ្យដែលទទួលមុនពេលបញ្ជូន រៀបចំឲ្យមានបុគ្គលិកសុខាភិបាលទៅជាមួយអ្នកជំងឺ ត្រូវមានឱសថសង្គ្រោះជីវិត សម្ភារៈសម្រាប់ដឹកជញ្ជូន និងប័ណ្ណកំណត់ត្រាអ្នកជំងឺ ដោយមានឯកសារច្បាស់លាស់អំពីប្រវត្តិ និងការព្យាបាលផ្សេងៗកន្លងមក
- ○ ផ្តល់ការថែទាំក្រោយពេលសម្រាលឲ្យបានសមស្រប។

**មាតិកានៃសមត្ថភាពស្នូល** សម្រាប់**ការពិនិត្យព្យាបាលផ្នែកជំងឺវេជ្ជសាស្ត្រ ជំងឺវះកាត់ ជំងឺកុមារ សម្ភពនិងរោគស្ត្រី** ត្រូវបានរៀបរាប់ក្នុងឧបសម្ព័ន្ធទី៥។

## ជំពូកទី៣៖ ឥរិយាបថវិជ្ជាជីវៈ និង ឥរិយាបថផ្ទាល់ខ្លួន
## (Professional and Personal Behaviours)

### *ក. ការប្រតិបត្តិ ប្រកបដោយ វិជ្ជាជីវៈ តាមច្បាប់ និង ក្រមសីលធម៌*
### (Professional and Legal-Ethical Practice)

ផ្នែកនេះបរិយាយពីស្តង់ដារចំនួនបួន ក្នុងការថែទាំព្យាបាលជម្ងឺ ប្រកបដោយវិជ្ជាជីវៈ តាមច្បាប់ និង ក្រមសីលធម៌។

**១.ការប្រតិបត្តិច្បាប់ និងក្រមសីធម៌ (Legal and Ethical Practice)**

គ្រូពេទ្យព្យាបាលជំងឺទូទៅ៖

- ដឹងពីទិដ្ឋភាពទាំងអស់នៃច្បាប់វេជ្ជសាស្ត្រ ព្រមទាំងក្រិត្យក្រម និងសេចក្តីប្រកាសដែលពាក់ព័ន្ធទៅនិងការប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ នៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងវិសោធនកម្មនានាដែលអាចកើតមានក្នុងពេលបន្តបន្ទាប់
- ប្រកបវិជ្ជាជីវៈ តាមស្តង់ដារក្រមសីលធម៌ឬក្រិត្យក្រមច្បាប់ជាតិជាធរមាន និងគោលការណ៍ណែនាំនានា ដែលជាផ្នែកនៃល័ក្ខខ័ណ្ឌច្បាប់គ្របដណ្តប់លើការប្រតិបត្តិអាជីពវេជ្ជសាស្ត្រ
- អនុវត្តតាមលក្ខន្តិកៈនៃក្រមច្បាប់ក្នុងការប្រតិបត្តិសម្រាប់គ្រូពេទ្យព្យាបាល និងគោលការណ៍ក្រមសីលធម៌ ដែលទាក់ទងនឹងការប្រតិបត្តិអាជីពវេជ្ជសាស្ត្រ ឧទា. ការរក្សាការសម្ងាត់ ការរក្សាភាពអៀនខ្មាស (privacy) និងការព្រមព្រៀងរបស់អ្នកជំងឺ។

**២. ការលើកកំពស់ មុខមាត់ និងកេរ្តិ៍ឈ្មោះនៃវិជ្ជាជីវៈ**

**(Good Standing and Reputation of the Profession)**

គ្រូពេទ្យព្យាបាលជំងឺទូទៅ៖

- មានសុចរិតភាពជាបុគ្គលនិងក្នុងការប្រកបវិជ្ជាជីវៈ
- រួមចំណែកដល់ការបង្កើនគុណភាពសេវាកម្ម
- រក្សា និងបង្កើនគុណភាពសេវាកម្ម។

**៣. ការថែទាំព្យាបាលជម្ងឺប្រកបដោយសុវត្ថិភាព (Safe Medical Practice)**

គ្រូពេទ្យព្យាបាលជំងឺទូទៅ៖

- ទទួលខុសត្រូវ និងដោះស្រាយរាល់កង្វះខាតនៃការប្រកបវិជ្ជាជីវៈរបស់ខ្លួន

- ធ្វើអន្តរាគមន៍ភ្លាមក្នុងខណៈកើតមានឧប្បត្តិហេតុនៃការព្យាបាលដើម្បីកាត់បន្ថយគ្រោះថ្នាក់ឲ្យមកនៅតិចបំផុត និង/ឬបង្ការការកើតឡើងសារជាថ្មីទៀត
- យល់ពីទំនួលខុសត្រូវក្នុងការជូនដំណឹងដល់អ្នកជំងឺពីឧប្បត្តិហេតុនៃការព្យាបាលដែលអាចមានផលប៉ះពាល់ដល់សុខភាព ឬសុខុមាលភាពរបស់ពួកគេ
- កត់ត្រារាល់កំហុសឆ្គងនៃការព្យាបាលរួមទាំងវិធានការកាត់បន្ថយផលប៉ះពាល់លើអ្នកជំងឺឲ្យមកនៅតិចបំផុត និង/ឬបង្ការការកើតឡើងសារជាថ្មីទៀត។

### ៤. កិច្ចសហការ និងការធ្វើការងារជាក្រុម (Collaboration and Team Working)

គ្រូពេទ្យព្យាបាលជំងឺទូទៅៈ

- ប្រើជំនាញក្នុងការប្រាស្រ័យទាក់ទងដោយពាក្យសំដី អាកប្បកិរិយា ការស្តាប់ និងការសរសេរប្រកបដោយប្រសិទ្ធភាព ដើម្បីធ្វើការប្រាស្រ័យទាក់ទងឲ្យបានច្បាស់ ជាក់លាក់ និងត្រឹមត្រូវជាមួយនឹងអ្នកជំងឺ អ្នកកំដរ បុគ្គលិកសុខាភិបាល បុគ្គលិកជំនួយការដទៃ ទៀត និងភាគីទី៣ផ្សេងៗទៀតដែលពាក់ព័ន្ធ
- មានសមត្ថភាពកសាងទំនាក់ទំនងប្រកបដោយវិជ្ជមានជាមួយនឹងអ្នកជំងឺ អ្នកកំដរ សហការី និងបុគ្គលិកសុខាភិបាលដទៃទៀត
- ចូលរួមសហការ និងផ្តល់យោបល់ស្តីពីការធ្វើការសម្រេចចិត្តព្យាបាល និងការបញ្ជូនជំងឺដោយសមស្របទៅកាន់ក្រុមការងារពហុជំនាញ
- សហការជាមួយនឹងបុគ្គលិកសុខាភិបាលដទៃទៀត ដើម្បីព្យាបាលថែទាំអ្នកជំងឺឲ្យបានប្រសើរ។

## *ខ .ការអភិវឌ្ឍន៍សមត្ថភាពវិជ្ជាជីវៈបន្ត (Continuing Professional Development)*

គ្រូពេទ្យព្យាបាលជំងឺទូទៅ តម្រូវឲ្យយល់ និងទទួលខុសត្រូវលើការសិក្សាបន្ត (រហូតមួយជីវិត) ក្នុងបំណងលើកកំពស់ជំនាញ ឬសមត្ថភាពរបស់ពួកគេ ដែលជាមធ្យោបាយក្នុងការជំរុញអាជីព និងតួនាទីវិជ្ជាជីវៈរបស់ពួកគេក្នុងសហគមន៍។ គេរំពឹងថាការតម្រូវនេះនឹងក្លាយជាកាតព្វកិច្ចសម្រាប់គ្រូពេទ្យព្យាបាលជំងឺទូទៅទាំងអស់នៅក្នុងប្រទេសកម្ពុជានាពេលអនាគត។

កម្មវិធីសិក្សា និងវិធានការសម្រាប់ការបណ្តុះបណ្តាលបន្តនឹងត្រូវបានរៀបចំឡើងដោយគណៈគ្រូពេទ្យកម្ពុជា។ គ្រូពេទ្យព្យាបាលដែលបានចុះឈ្មោះម្នាក់ៗនឹងតម្រូវឲ្យអនុវត្តនូវកាតព្វកិច្ចនេះ និងត្រូវភស្តុតាងដែលបញ្ជាក់ពីក្រេឌីតនៃការបណ្តុះបណ្តាលបន្ត ដើម្បីរក្សាឈ្មោះរបស់ពួកគេនៅក្នុងបញ្ជីគ្រូពេទ្យដែលបានចុះឈ្មោះក្នុងប្រទេសកម្ពុជាដោយទៀង។

## គ. ការវិភាគល្អិតល្អន់ ការស្រាវជ្រាវ និងការបណ្តុះបណ្តាល
**(Critical Analysis, Research and Education)**

ផ្នែកនេះបង្ហាញពីសមត្ថភាពជំនាញរបស់គ្រូពេទ្យព្យាបាលជំងឺទូទៅក្នុង (ក)ការវិភាគ និងការសំយោគព័ត៌មានពីអត្ថបទ ឬឯកសារផ្សព្វផ្សាយផ្នែកវេជ្ជសាស្ត្រ (ខ)កិច្ចអនុវត្តការស្រាវជ្រាវដែលពាក់ព័ន្ធក្នុងផ្នែកវេជ្ជសាស្ត្រ និងបណ្តុះបណ្តាលអ្នកដទៃទៀត។

### ១. ស្វែងរក វិភាគ និងសំយោគព័ត៌មាន (Access, Analysis and Synthesis of Information)

គ្រូពេទ្យព្យាបាលជំងឺទូទៅៈ
- ចេះរកមើល វិភាគ និងសំយោគព័ត៌មានគ្លីនីក និងសុខភាព ព្រមទាំង
- ប្រើប្រាស់ពត៌មានដែលទទួលបានដើម្បីឆ្លើយអោយបានសមស្រប(ជាលាយលក្ខណ៍អក្សរ និង/ឬដោយផ្ទាល់មាត់)ចំពោះសំណួរ ឬសំណើសម្រាប់ព័ត៌មានរបស់អតិថិជនជាធម្មតាឬជាផ្លូវការ និង/ឬដើម្បីបម្រើសកម្មភាពស្រាវជ្រាវ។

### ២. ចូលរួមក្នុងការស្រាវជ្រាវ និងការបណ្តុះបណ្តាល (Research and Education)

គ្រូពេទ្យព្យាបាលជំងឺទូទៅត្រូវៈ
- អនុវត្តសកម្មភាពស្រាវជ្រាវ
- អនុវត្តវិធីសាស្ត្រស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ដើម្បី ស្រាវជ្រាវបញ្ហាដែលជាប់ទាក់ទងទៅនឹងការប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ
- យល់ និងអនុវត្តគោលការណ៍ក្រមសីលធម៌នៃការស្រាវជ្រាវ
- អនុវត្ត និងផ្សព្វផ្សាយរបកគំហើញនៃការស្រាវជ្រាវ
- បណ្តុះបណ្តាល និស្សិតពេទ្យ និងសហការីពាក់ព័ន្ធ។

## ឃ. ការប្រាស្រ័យទាក់ទង (Communication)
គ្រូពេទ្យព្យាបាលជំងឺទូទៅត្រូវចេះប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជាមួយនឹងៈ

### ១.អ្នកជំងឺ (និងក្រុមគ្រួសារ) តាមរយៈ
- ការពន្យល់ច្បាស់លាស់ ដើម្បីទទួលបានការព្រមព្រៀងពីអ្នកជំងឺឲ្យពិនិត្យព្យាបាល
- ការដោះស្រាយនូវការត្អូញត្អែររបស់អ្នកជំងឺ និងស្ថានភាពលំបាកដទៃទៀតប្រកបដោយប្រសិទ្ធភាព

- ការផ្ដល់ប្រឹក្សាដល់អ្នកជំងឺលើបញ្ហាសុខភាពផ្សេងៗ និងការបង្ការជំងឺ។

## ២. សហការី តាមរយៈ

- ការផ្ដល់និងចែករំលែកព័ត៌មានដោយផ្ទាល់មាត់ ដោយសរសេរ និងតាមប្រព័ន្ធអេឡិចត្រូនិក
- ការសរសេរប័ណ្ណបញ្ជូនអ្នកជំងឺ
- ការផ្ដល់ទៅសហការីទាំងអស់ដែលពាក់ព័ន្ធ នូវព័ត៌មានគ្លីនីកដែលចាំបាច់។

## ឧបសម្ព័ន្ធទី១៖ សមាសភាពក្រុមការងាររៀបរៀងសាស្ត្រ

| | | | |
|---|---|---|---|
| ១-ឯកឧត្តមសាស្ត្រាចារ្យ | យីត ស៊ុនណារ៉ា | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សហប្រធាន |
| ២-លោក | យូ វីរៈ | អនុប្រធាននាយកដ្ឋានឧត្តមសិក្សា អ.យ.ក | សហប្រធាន |
| ៣-លោកវេជ្ជបណ្ឌិត | ប៊ុន ស្រីវ | នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស | សមាជិកអចិន្ត្រៃយ៍ |
| ៤-លោក | អ៊ឹង ឆាយប៉ោ | នាយកដ្ឋានឧត្តមសិក្សាអ.យ.ក | សមាជិកអចិន្ត្រៃយ៍ |
| ៥-ឯកឧត្តមសាស្ត្រាចារ្យ | ញ៉ែម សូភៀន | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៦-ឯកឧត្តមសាស្ត្រាចារ្យ | គុំ កាណាល់ | ទីប្រឹក្សាក្រសុខាភិបាល | សមាជិក |
| ៧-លោកសាស្ត្រាចារ្យ | ឡាំ អេងហួរ | តំណាងគណៈគ្រូពេទ្យ | សមាជិក |
| ៨-លោកសាស្ត្រាចារ្យ | ប្រាក់ សេងហួរ | សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល | សមាជិក |
| ៩-លោកសាស្ត្រាចារ្យ | តាន់ តឹកស្រេង | សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល | សមាជិក |
| ១០-លោកស្រីសាស្ត្រាចារ្យ | ហ៊ី សូព្រាភា | សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល | សមាជិក |
| ១១-លោកសាស្ត្រាចារ្យ | អ៊ាប តឹកឆេង | សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល | សមាជិក |
| ១២-លោកសាស្ត្រាចារ្យ | ឈិន សែនយ៉ា | សាកលវិទ្យាល័យអន្តរជាតិ | សមាជិក |
| ១៣-លោកសាស្ត្រាចារ្យរង | ស៊ិក ធីរៈ | សាកលវិទ្យាល័យអន្តរជាតិ | សមាជិក |
| ១៤-លោកស្រីសាស្ត្រាចារ្យ | ស្រី សូផា | សាកលវិទ្យាល័យអន្តរជាតិ | សមាជិក |
| ១៥- លោកសាស្ត្រាចារ្យ | អ៊ុង សុផល | សាកលវិទ្យាល័យអន្តរជាតិ | សមាជិក |
| ១៦-លោកសាស្ត្រាចារ្យជំ. | សរ កែវរ៉ាវង្ស | វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល ខ.ភ.ម | សមាជិក |
| ១៧-លោកវេជ្ជបណ្ឌិត | នៅ កំសាន្ត | វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល ខ.ភ.ម | សមាជិក |
| ១៨-លោកសាស្ត្រាចារ្យជំ. | ស៊ិន តារាវុធ | វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល ខ.ភ.ម | សមាជិក |
| ១៩-លោកសាស្ត្រាចារ្យជំ. | សេង សុមេធ | វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល ខ.ភ.ម | សមាជិក |

## អ្នកពិនិត្យនិងផ្តល់យោបល់៖

សាស្ត្រាចារ្យ Jim Logerfo, សាកលវិទ្យាល័យ Washington, សហរដ្ឋអាមេរិក
វេជ្ជ. Howard Lawrence, អង្គការសុខភាពពិភពលោក ភ្នំពេញ
វេជ្ជ. Fujita Massami, អង្គការសុខភាពពិភពលោក ភ្នំពេញ
វេជ្ជ. Maria Coneption, អង្គការសុខភាពពិភពលោក ភ្នំពេញ
វេជ្ជ. Nima Asgari, អង្គការសុខភាពពិភពលោក ភ្នំពេញ
សាស្ត្រាចារ្យ អ៊ុំ សុផល ក្រសួងសុខាភិបាល

## ឧបសម្ព័ន្ធទី២៖ សមាសភាពគណៈកម្មការសំរបសំរួល

| | | | |
|---|---|---|---|
| ១-ឯកឧត្តមសាស្ត្រាចារ្យ | ធា គ្រុយ | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ប្រធាន |
| ២-ឯកឧត្តមសាស្ត្រាចារ្យ | យឹត ស៊ុនណារ៉ា | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៣-ឯកឧត្តម | លី សុមុនី | អនុរដ្ឋលេខាធិការក្រសួងអ.យ.ក | អនុប្រធាន |
| ៤-ឯកឧត្តម | ម៉ៅ ប៊ុននិន | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគ.ទ.ក | សមាជិក |
| ៥-លោកស្រីសាស្ត្រាចារ្យ | គាត ភួង | ប្រធានលេខាធិការដ្ឋានប្រឡងថ្នាក់ជាតិ | សមាជិកអចិន្ត្រៃយ៍ |
| ៦-លោកវេជ្ជបណ្ឌិត | ភុំ សំសុង | អនុប្រធានលេខាធិការដ្ឋានប្រឡងថ្នាក់ជាតិ | សមាជិក |
| ៧-លោកស្រី | ម៉ក់ ណាង | អនុប្រធានលេខាធិការដ្ឋានប្រឡងថ្នាក់ជាតិ | សមាជិក |
| ៨-កញ្ញាវេជ្ជបណ្ឌិត | ទូច សុខនាង | លេខាធិការដ្ឋានប្រឡងថ្នាក់ជាតិ | សមាជិក |
| ៩-លោកវេជ្ជបណ្ឌិត | វើង ឆាយ | លេខាធិការដ្ឋានប្រឡងថ្នាក់ជាតិ | សមាជិក |
| ១០-លោកស្រី | ឆេង ចាន់ណារី | លេខាធិការដ្ឋានប្រឡងថ្នាក់ជាតិ | សមាជិក |
| ១១-លោក | អ៊ឹង ឆាយប៉ោ | លេខាធិការដ្ឋានប្រឡងថ្នាក់ជាតិ | សមាជិក |
| ១២-លោក | កាក់ រចនា | លេខាធិការដ្ឋានប្រឡងថ្នាក់ជាតិ | សមាជិក |
| ១៣-លោក | មាស វណ្ណថា | លេខាធិការដ្ឋានប្រឡងថ្នាក់ជាតិ | សមាជិក |
| ១៤-លោកវេជ្ជបណ្ឌិត | ប៊ុន ស្រ៊ីវ | លេខាធិការដ្ឋានប្រឡងថ្នាក់ជាតិ | សមាជិក |
| ១៥-លោកស្រី | លឹម រត្ននារី | លេខាធិការដ្ឋានប្រឡងថ្នាក់ជាតិ | សមាជិក |
| ១៦-លោកសាស្ត្រាចារ្យ | យក់ សូផាន់ណា | សាកលវិទ្យាធិការ នៃស.វ.ស | សមាជិក |
| ១៧-លោកសាស្ត្រាចារ្យ | សាផុន វឌ្ឍនៈ | សាកលវិទ្យាធិការរង នៃស.វ.ស | សមាជិក |
| ១៨-លោកបណ្ឌិត | សឿន សម្បត្តិ | សាកលវិទ្យាល័យអន្តរជាតិ | សមាជិក |
| ១៩- លោកបណ្ឌិត | ទន់ សុខសម្បត្តិ | សាកលវិទ្យាល័យអន្តរជាតិ | សមាជិក |
| ២០-លោកសាស្ត្រា.ជំ | គីម ខត្តរី | វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល ខ.ភ.ម | សមាជិក |
| ២១-លោកសាស្ត្រា.ជំ | លុក សាវ៉ាង | វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល ខ.ភ.ម | សមាជិក |
| ២២-លោក | ស្រ៊ុន ជីវ៉ែន | សាកលវិទ្យាល័យ ឡាយហ្វ | សមាជិក |
| ២៣-លោក | ជ្រិន ម៉ាក់ | សាកលវិទ្យាល័យ ឡាយហ្វ | សមាជិក |

## ឧបសម្ព័ន្ធទី៣៖ លក្ខណៈសម្បត្តិរបស់គ្រូពេទ្យព្យាបាលជំងឺទូទៅ

(Profile of GPs in Cambodia)

**តួនាទី៖** (១) គ្រូពេទ្យព្យាបាលជំងឺទូទៅ (២) អ្នកវិទ្យាសាស្ត្រ និងអ្នកស្រាវជ្រាវ និង (៣) អ្នកប្រកបវិជ្ជាជីវៈអាជីព

**ទីកន្លែងធ្វើការ៖** (១)មន្ទីរពេទ្យរដ្ឋ (២)មន្ទីរពេទ្យឬគ្លីនីកឯកជន (៣)គ្លីនីកតាមផ្ទះ

**ភារកិច្ច៖**

គ្រូពេទ្យព្យាបាលជំងឺទូទៅ ផ្តល់សេវាថែទាំសុខភាពថ្នាក់ដំបូងឬទូទៅ ដល់អ្នកជំងឺក្នុងព្រំដែននៃសមត្ថភាពជំនាញរបស់ពួកគេ និងធនធានដែលមាន បើមិនដូច្នេះទេ ត្រូវបញ្ជូនអ្នកជំងឺទៅអ្នកជំនាញខាងព្យាបាលថែទាំសុខភាព និងមូលដ្ឋានសុខភិបាលដទៃទៀត។

គ្រូពេទ្យព្យាបាលជំងឺទូទៅ ដោយសហការជាមួយអតិថិជន និងអ្នកផ្តល់សេវាថែទាំសុខភាពដទៃទៀត ត្រូវផ្តល់សេវាវេជ្ជសាស្ត្រដែលមានស្តង់ដារខ្ពស់ដល់អ្នកជំងឺ ដោយគោរពការសម្ងាត់ សេចក្តីថ្លៃថ្នូរ និងភាពសុចរិត ដោយមិនគិតពីស្ថានភាពសង្គម សេដ្ឋកិច្ច និងនិន្នាការនយោបាយឡើយ។

គ្រូពេទ្យព្យាបាលជំងឺទូទៅ មានសមត្ថភាពដើម្បីធ្វើការវាយតម្លៃសុខភាពសព្វគ្រប់ និងមានលក្ខណៈជាប្រព័ន្ធ ដើម្បីធ្វើរោគវិនិច្ឆ័យលើស្ថានភាពសុខភាពឬជំងឺ និងដើម្បីព្យាបាល គ្រប់គ្រងទាំងជំងឺស្រួចស្រាវ និងរ៉ាំរ៉ៃ។

គ្រូពេទ្យព្យាបាលជំងឺទូទៅ ស្នើសុំ និងបកស្រាយតេស្តសម្រាប់ធ្វើរោគវិនិច្ឆ័យ និងស្រាវជ្រាវជំងឺ អនុវត្តទម្រង់ការគ្លីនីក និងចេញវេជ្ជបញ្ជាព្យាបាលដោយអនុលោមតាមច្បាប់ និងគោលនយោបាយរបស់ក្រសួងសុខាភិបាល។

គ្រូពេទ្យព្យាបាលជំងឺទូទៅ ផ្តល់ការអប់រំសុខភាព និងផ្តល់ប្រឹក្សាដល់អ្នកជំងឺស្តីពីការលើកកម្ពស់សុខភាព ព្រមទាំងការបង្ការជំងឺ និងស្តារសុខភាពឡើងវិញឲ្យបានត្រឹមត្រូវ។

គ្រូពេទ្យព្យាបាលជំងឺទូទៅ ចូលរួមក្នុងការតាមដានជំងឺ និងបញ្ហាសុខភាពផ្សេងទៀតតាមការតម្រូវរបស់ក្រសួងសុខាភិបាល និងចូលរួមចំណែកក្នុងការលើកកម្ពស់សុខភាព និងបង្ការជំងឺ។

គ្រូពេទ្យព្យាបាលជំងឺទូទៅ ផ្តល់ការបណ្តុះបណ្តាលដល់និស្សិត និងបុគ្គលិកសុខាភិបាល។

គ្រូពេទ្យព្យាបាលជំងឺទូទៅ មានការទទួលខុសត្រូវ និងគណនេយ្យភាពសម្រាប់ប្រកបវិជ្ជាជីវវេជ្ជសាស្ត្រល្អ ព្រមទាំងបង្កើនជំនាញ និងចំណេះដឹងរបស់ពួកគេតាមរយៈការបណ្តុះបណ្តាលវេជ្ជសាស្ត្របន្ត ការស្រាវជ្រាវ និងអភិវឌ្ឍន៍។

## ឧបសម្ព័ន្ធទី៤៖ មូលដ្ឋានវិទ្យាសាស្ត្រសំរាប់ការអនុវត្តន៍វិជ្ជាជីវៈវេជ្ជសាស្ត្រ
(Competency Contents on Scientific Foundation for Medical Practice)

### *ក.វិទ្យាសាស្ត្រវេជ្ជជីវសាស្ត្រ (Biomedical Sciences)*

១. **កាយវិភាគវិទ្យា សរីរវិទ្យា** និង**សរីររោគវិទ្យា** (Anatomy, Physiology, and Physio-pathology)

រចនាសម្ព័ន្ធ និងមុខងារធម្មតាព្រមទាំងដំណើរការមិនប្រក្រតីនៃប្រព័ន្ធសរីរាង្គ៖

- បង្កើតគ្រាប់ឈាម(ក្រហម និងស) (Hematopoietic/lympho-reticular)
- សរសៃប្រសាទ (Nervous/special senses)
- ស្បែក (Skin/connective tissue)
- សាច់ដុំឆ្អឹង (Musculoskeletal)
- ដង្ហើម
- បេះដូង និងសរសៃបេះដូង
- ក្រពះ ពោះវៀន
- តម្រងនោម
- បន្តពូជ
- អង់ដូគ្រីន (Endocrine)
- ការពាររាង្គកាយ(Immune system)

២. **ជីវគីមីវិទ្យា** (Biochemistry)

- ដំណើរការ និងបែបបទមេតាបូលិកនៃជំងឺ
- ដំណើរការផ្នែកហ្សែន និងអ៊ីមូណូវិទ្យានៃជំងឺ
- សណ្ឋានគ្លីនិកនៃជំងឺកង្វះអាហាររូបត្ថម្ភ

៣. **មីក្រូជីវវិទ្យា** (Microbiology)

- ភ្នាក់ងារមីក្រូជីវវិទ្យា (មេរោគ)នៃជំងឺ និងបញ្ហាសុខភាព
- គំរូវិភាគដែលត្រូវយក ព្រមទាំងបែបបទមន្ទីរពិសោធន៍សម្រាប់វិភាគរកមេរោគ ចំពោះអ្នកជំងឺដែលសង្ស័យថាមានការចម្លងរោគ
- វិធានការព្យាបាល និងត្រួតពិនិត្យភ្នាក់ងារបង្ករោគ

៤. **រោគវិទ្យា** (Pathology)

- រចនាសម្ព័ន្ធផ្នែករោគវិទ្យា(pathology) ឬរូបវិទ្យា (morphology)នៃបញ្ហាគ្លីនិក ឬជំងឺ
- ដំណើរការសរីររោគវិទ្យា (pathophysiological process ) នៃជំងឺដែលតែងជួបប្រទះញឹកញាប់
- ដំណើរវិវត្តតាមធម្មជាតិរបស់ជំងឺ ឬបញ្ហាសុខភាពដែលរួមមាន៖ ជំងឺឆ្លង ជំងឺប្រព័ន្ធបេះដូង ឬសរសៃបេះដូង ប្រព័ន្ធដង្ហើម ប្រព័ន្ធទឹកនោម ប្រព័ន្ធក្រពះពោះវៀន ប្រព័ន្ធថ្លើម និងលំពែង ប្រព័ន្ធបន្តពូជ ប្រព័ន្ធអង់ដូគ្រីន និងប្រព័ន្ធឆ្អឹងឬសាច់ដុំ។

### ៥. **ហ្វាម៉ាកូវិទ្យា** (Pharmacology)

យន្តការនៃសកម្មភាពរបស់ឱសថ កំរិតប្រើប្រាស់(kinetics) ឥទ្ធិពលបន្ទាប់បន្សំ និងការហាមប្រើនៃឱសថដែលត្រូវបានប្រើញឹកញាប់សម្រាប់៖

- ការព្យាបាលជំងឺបង្ករដោយមេរោគ ដោយប្រើថ្នាំឬជាតិគីមី (Chemotherapy of microbial diseases)
- ការព្យាបាលជំងឺប៉ារ៉ាស៊ីត ដោយប្រើថ្នាំឬជាតិគីមី(Chemotherapy of parasitic diseases)
- ថ្នាំព្យាបាលជំងឺបេះដូង និងសរសៃឈាម (Cardiovascular drugs)
- ថ្នាំព្យាបាលការរលាក (Drug therapy of inflammation)
- ថ្នាំព្យាបាលជំងឺប្រព័ន្ធសរសៃប្រសាទ (Drugs acting on nervous system)
- ថ្នាំព្យាបាលផ្លូវរំលាយអាហារ (Drugs affecting the gastrointestinal tract)
- ពពួកអ័រម៉ូន និងបដិអ័រម៉ូន (Hormones and hormone antagonists)

### ៦. **ក្រមសីលធម៌វេជ្ជសាស្ត្រ** (Medical Ethics)

- ប្រភេទនៃភាពទទួលខុសត្រូវរបស់គ្រូពេទ្យទាក់ទិនទៅនឹងការប្រកបវិជ្ជាជីវៈ
- ឥរិយាបថសមស្របរបស់គ្រូពេទ្យចំពោះអ្នកជំងឺ

## *ខ. វិទ្យាសាស្ត្រឥរិយាបថ (Behavioral Sciences)*

- ឥរិយាបថធម្មតារបស់មនុស្សក្នុងកំរិតបុគ្គល និងសង្គម
- ទស្សនៈ ចិត្តសាស្ត្រ សង្គមនៃសុខភាព និងជំងឺ
- ក្របខ័ណ្ឌទ្រឹស្តីនៃចិត្តសាស្ត្រ និងសង្គមសម្រាប់ពន្យល់ លើការឆ្លើយតបរបស់បុគ្គល ក្រុមជន និងសង្គម ទៅនឹងជំងឺ
- កត្តាចិត្តសាស្ត្រ និងសង្គមដែលរួមចំណែកដល់ការមានជំងឺ ដំណើរវិវត្តនៃជំងឺ និងជោគជ័យឬលទ្ធផលនៃការព្យាបាល
- ទិដ្ឋភាពចិត្តសាស្ត្រ និងសង្គមក្នុងការផ្លាស់ប្តូរឥរិយាបថ ព្រមទាំងការអនុវត្តន៍ការព្យាបាលដោយទៀងទាត់
- យុទ្ធសាស្ត្រសម្រាប់ព្យាបាលអ្នកជំងឺដែលមានបញ្ហាញៀនថ្នាំនិងធ្វើអោយរងរបួសខ្លួនឯង

### គ. សុខភាពសាធារណៈ (Public Health)

- កត្តាកំណត់នៃជំងឺ ការលើកកំពស់សុខភាព និងបង្ការជំងឺ
- ការតាមដាន និងរុករកជំងឺ
- ការផ្តល់សេវាថែទាំ និងព្យាបាលជំងឺចំពោះបុគ្គល និងសហគមន៍
- យុទ្ធសាស្រ្តនៃការធ្វើអន្តរាគមន៍ និងកាត់បន្ថយហានិភ័យសម្រាប់អ្នកជំងឺម្នាក់ៗ និងសហគមន៍
- វិធីសម្រាប់បង្ការ ត្រួតពិនិត្យការឆ្លងរោគ និងជំងឺឆ្លងនៅមន្ទីរពេទ្យ និងសហគមន៍

### ឃ. ការស្រាវជ្រាវ និងផ្សព្វផ្សាយពត៌មាន (Research and Communication)

- វិធីរក រក្សា និងទាញយកពត៌មានពីប្រព័ន្ធអាំងទែណែត
- គោលការណ៍ និងវិធីផ្សព្វផ្សាយក្នុងការប្រាស័យទាក់ទង
- គោលការណ៍ និងវិធីស្រាវជ្រាវគ្លីនិកនិងសុខភាព
- បញ្ហាក្រមសីលធម៌ និងគ្រប់គ្រងក្នុងការស្រាវជ្រាវវេជ្ជសាស្រ្ត
- វិធីវាយតម្លៃដោយស្មារតីទិតៀនចំពោះអត្ថបទវេជ្ជសាស្រ្ត

## ឧបសម្ព័ន្ធទី៥៖ មាតិកាសមត្ថភាពសម្រាប់ការពិនិត្យព្យាបាលជំងឺ
(Patient Management)

### *ក. មាតិកាសមត្ថភាពស្នូលផ្នែកវេជ្ជសាស្ត្រ*
(Core Competency Contents in Medicine)

១. ទម្រង់ការសម្រាប់ការព្យាបាលជំងឺទូទៅ (General Medical Management Procedures)

- ការសង្គ្រោះបន្ទាន់ចំពោះបេះដូងនិងសួត (Cardiopulmonary resuscitation)
- ការព្យាបាលទាក់ទិនទៅនឹងវត្ថុរាវ និងអេឡិចត្រូលីត (Fluid and electrolyte management)
- ការគាំទ្រផ្នែកដំណកដង្ហើម (Ventilatory support)
- វិធានការសង្គ្រោះបឋម (First aid measures)
- ការគាំទ្រជីវិតមូលដ្ឋាន (Basic life support)
- ការដឹកជញ្ជូនអ្នកជំងឺឲ្យបានត្រឹមត្រូវ (Proper transport of patients)
- ការគ្រប់គ្រងស្ដុក (Management of shock)
- អនាម័យ និងភាពស្អាតបាត (Hygiene and sanitation)
- អាហារូបត្ថម្ភត្រឹមត្រូវ និងលំហាត់ប្រាណ (Proper nutrition and exercise)
- ការចាក់ថ្នាំបង្ការ (Immunization)។

**២ . ជំងឺសង្គ្រោះបន្ទាន់ដែលជួបញឹកញាប់ (Common Medical Emergencies)**

**២.១** ការគាំង បេះដូងនិងសួត (Cardiopulmonary collapse, arrest)

- ភាពមិនប្រក្រតីនៃអត្រាចង្វាក់បេះដូង និងចង្វាក់ដង្ហើម
- ហើមសួត(Pulmonary edema)ការច្រាលឈាមនៃបេះដូងដោយសារការស្លាក់ឈាម(congestive heart failure)
- ការស្ទែកសាច់ដុំបេះដូងស្រួចស្រាវ(Acute myocardial infarction)

**២.២** ការបាត់តួនាទីដំណកដង្ហើម(Respiratory failure)

**២.៣** ជំងឺសង្គ្រោះបន្ទាន់ក្រពះពោះវៀន (ការហូរឈាមដែលបណ្ដាលមកពីក្រពះពោះវៀន រោគខួរក្បាលដែលបណ្ដាលមកពីបញ្ហាថ្លើម(Hepatic encephalopathy))

**២.៤** ជំងឺសង្គ្រោះបន្ទាន់ដែលបណ្ដាលមកពីបញ្ហាអង់ដូគ្រីន

**២.៥** ជំងឺសង្គ្រោះបន្ទាន់ដែលបណ្ដាលមកពីបញ្ហាឈាម(Hematologic emergencies)

- ការហូរឈាម ការកកឈាមដែលសាយភាយពេញសរសៃ (disseminated intravascular coagulation)

២.៦ ជំងឺសង្គ្រោះបន្ទាន់ដែលបណ្តាលមកពីបញ្ហាសរសៃប្រសាទ(Neurologic emergencies)

- ជំងឺខួរក្បាលនិងសរសៃឈាម(Cerebrovascular disease)
- ការកើនសម្ពាធក្នុងប្រអប់ក្បាល(Increased intracranial pressure)
- ការប្រកាច់ ជំងឺឆ្កួតជ្រូក(Seizure, status epilepticus)

២.៧ ជំងឺសង្គ្រោះបន្ទាន់ដែលបណ្តាលមកពីបញ្ហាស្បែក

២.៨ ការខូចប្រព័ន្ធសរីរាង្គច្រើន (Multiple organ system failure)

២.៩ ជំងឺសង្គ្រោះបន្ទាន់ដែលបណ្តាលមកពីបញ្ហាមេតាបូលិក។

## ៣. ជំងឺទូទៅដែលជួបញឹកញាប់ (Common Medical Conditions)

៣.១ ប្រព័ន្ធបេះដូងសរសៃឈាម (Cardiovascular System)

- ការស្ទះឬច្រាលឈាមនៃបេះដូងដោយសារការស្លាក់ឈាម(Congestive heart failure), cor pulmonale
- បញ្ហាលើសឈាម (តេស្តស្រាវជ្រាវបញ្ហាលើសឈាមដែលកើតដោយខ្លួនឯង ធៀបនឹងបញ្ហាលើសឈាមដែលជាផលវិបាកនៃជំងឺផ្សេង)
- វិបត្តិចង្វាក់បេះដូង(Arrhythmias) (វិបត្តិចង្វាក់បេះដូងដើរញាប់ និងមិនស្មើ គាំង (blocks))
- ជំងឺសរសៃឈាមបេះដូង(Valvular heart disease) (ជំងឺបេះដូងដែលបណ្តាលមកពីរលាកសន្លាក់ឆ្អឹង ជំងឺស្ទះសន្ទះបេះដូងមីត្រាល់(Mitral stenosis) ជំងឺច្រាលឈាមថយក្រោយដោយសារសន្ទះបេះដូងមីត្រាល់បិទមិនជិត(Mitral regurgitation) ជំងឺខ្សោយសន្ទះបេះដូងមីត្រាល់(mitral valve prolapsed) ជំងឺច្រាលឈាមថយក្រោយដោយសារសន្ទះសរសៃឈាមអាអ័របិទមិនជិត(aortic regurgitation) ជំងឺសន្ទះ សរសៃឈាមអាអ័របើកមិនអស់(aortic insufficiency) ជំងឺច្រាលឈាមថយក្រោយដោយសារសន្ទះបេះដូងទ្រីគូស្ពីដបិទមិនជិត (tricuspid regurgitation) ជំងឺស្ទះសន្ទះបេះដូងទ្រីគូស្ពីដ(tricuspid stenosis))
- ជំងឺបេះដូងពីកំណើតក្នុងចំណោមមនុស្សពេញវ័យ (ថតបេះដូងខាងលើបិទមិនជិត(atrial septal defect) ថតបេះដូងខាងក្រោមបិទមិនជិត(ventricular septal defect) ការរត់ឆ្លងគ្នានៃឈាមរវាងសរសៃឈាមបេះបូងដែលបិទមិនជិត(patent ductus) ជំងឺសរសៃឈាមអាអ័ររួមតូចខុសធម្មតាពីកំណើត(coarctation of the aorta))

- ជំងឺរលាកសាច់ដុំបេះដូងផ្នែកខាងក្នុងដោយសារមេរោគ(Infective endocarditis)
- ជំងឺសរសៃឈាមបេះដូងក្ស៊ីនៃពាំរ៉ៃ (Chronic coronary artery disease)
- ជំងឺស្រោមបេះដូង(Pericardial disease) (ជំងឺរលាកស្រោមបេះដូងស្រួចស្រាវ និងរួមរិត)
- ជំងឺផ្សេងៗនៃសរសៃឈាមអាអ័រ(Diseases of the aorta) (ជំងឺប៉ោងសរសៃឈាមអាអ័រ(aortic aneurysm) aortic dissection)
- ជំងឺសរសៃឈាមផ្នែកខាងក្រៅ(Peripheral vascular disease)។

៣.២ ប្រព័ន្ធស្បែក (Integumentary System)

- ការឆ្លងរោគ (កមរមាស់ ជំងឺស្បែកដែលបណ្តាលមកពីពួកផ្សិត (dermatophyte infections), herpes simplex, រើម(herpes zoster) ឃ្លង់ ជំងឺឆ្លងបង្ករដោយមេរោគហ៊ីវ (HIV)
- ជំងឺរលាកស្បែកដោយការប៉ះពាល់(Atopic dermatitis)
- កន្ទាលត្រអាក(Urticaria)
- រោគមុន(Acne)
- ជំងឺមហារីកស្បែក(Skin cancer)
- វិបត្តិកន្ទួលរបកស្បែក(Papulo-squamous disorders)។

៣.៣ ប្រព័ន្ធអង់ដូគ្រីន(Endocrine System)

- ជំងឺទឹកនោមផ្អែម (Diabetes mellitus)
- រោគពកក(Goiter) ជំងឺលើសជាតិអ័រម៉ូន thyroid (hyperthyroidism) ជំងឺខ្វះជាតិអ័រម៉ូន thyroid (hypothyroidism)
- រោគខ្វះជាតិអ័រម៉ូន Adrenal (Adrenal insufficiency)
- បណ្តុំរោគសញ្ញា Cushing (Cushing's syndrome)
- វិបត្តិនៃ pituitary ផ្នែកខាងមុខ hypothalamus និងpituitary ផ្នែកខាងក្រោយ
- វិបត្តិនៃពងស្វាស និងប្រូស្តាត (Disorders of the testis and prostate)
- វិបត្តិនៃអណ្ឌាស័យ និងបំពង់ប្រដាប់ភេទស្ត្រី (Disorders of the ovary and female genital tract)។

៣.៤ វិបត្តិថ្លើម និងក្រពះពោះវៀន (Gastrointestinal and Liver Disorders)

- ជំងឺបំពង់អាហារធំ (ការពិបាកលេបអាហារ/ achalasia; ការច្រាលអាហារពីក្រពះមកបំពង់ក/ gastro-esophageal reflux disease))
- ជំងឺដំបៅក្រពះ(Peptic ulcer) និងវិបត្តិដែលទាក់ទងនឹងអាស៊ីតដទៃទៀត
- ដុំក្រពះពោះវៀន (បំពង់អាហារធំ ក្រពះ ពោះវៀនធំ មហារីកថ្លើម លំពែង និងដុំពោះវៀនធំ)

- ជំងឺពោះវៀនធំ និងរន្ធគូទចុងពោះវៀនធំ(Colonic and ano-rectal diseases) (irritable bowel syndrome, diverticular disease)
- រោគរលាកថ្លើម (ស្រួចស្រាវ ធៀបនឹងរ៉ាំរ៉ៃ ដោយសារវីរុស និងដោយសារជាតិអាល់កុល)
- ជំងឺក្រិនថ្លើម និងផលវិបាករបស់វា (ការឡើងសម្ពាធសរសៃវ៉ែនប៉ក(portal hypertension) រោគខួរក្បាល(encephalopathy) ទាចទឹក (ascites) រោគរលាកស្រោមពោះបង្ករពីបាក់តេរីដោយផ្ទាល់ (spontaneous bacterial peritonitis))
